**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២៧៧៤ អនក្រ.បក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
លេខ ៤៤៦
ថ្ងៃទី ១៥ ១២ ១១

# អនុក្រឹត្យ

## ស្ដីពី

## ការផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់

- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកេសូត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅៈ

- លើកកម្ពស់គុណភាពបណ្តុះបណ្តាលនៃគ្រឹះស្ថានឧត្តមសិក្សាក្នុងវិស័យកសិកម្ម
- លើកតម្កើងកិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់សាស្ត្រាចារ្យក្នុងវិស័យកសិកម្ម
- ចូលរួមចំណែករៀបចំនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យកសិកម្មឲ្យមានគុណភាពនិងប្រសិទ្ធភាពខ្ពស់
- លើកកម្ពស់ការទទួលខុសត្រូវនិងគុណវុឌ្ឍិរបស់សាស្ត្រាចារ្យក្នុងវិស័យកសិកម្ម
- បង្កើនកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សាក្នុងនិងក្រៅប្រទេសសម្រាប់ការបណ្តុះបណ្តាលធនធានមនុស្ស។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីយន្តការ នីតិវិធី និងលក្ខខណ្ឌនៃការជ្រើសរើសនិងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យនៅក្នុងវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# ក្រុមប្រឹក្សាជាតិត្រួតពិនិត្យការផ្ដល់ឋានៈ សាស្ត្រាចារ្យក្នុងវិស័យកសិកម្ម

**មាត្រា ៤.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិត្រួតពិនិត្យការផ្ដល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម សរសេរកាត់ថា **ក.ត.ស.ក.** ដែលមានសមាសភាពមកពី៖

| | | |
|---|---|---|
| – តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ រូប | ប្រធាន |
| – តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១ រូប | សមាជិក |
| – តំណាងក្រសួងអប់រំ យុវជន និងកីឡា | ១ រូប | សមាជិក |
| – តំណាងសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម | ៨ រូប | សមាជិក។ |

សមាសភាព **ក.ត.ស.ក.** មានអាណត្តិ៣(បី)ឆ្នាំ ហើយអាចបន្តអាណត្តិរបស់ខ្លួនសាជាថ្មីទៀត។

សមាសភាពដែលជាតំណាងសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សមាសភាពជាក់ស្ដែងនៃ **ក.ត.ស.ក.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា ៥.-**

**ក.ត.ស.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ៖

- អនុម័តនិងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់ **ក.ត.ស.ក.**
- កំណត់នីតិវិធីនិងបែបបទស្ដីពីការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើសមាសភាពគណៈមេប្រយោគ សម្រាប់វាយតម្លៃលើសាស្ត្រាចារ្យ
- អនុម័តយល់ព្រមលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ
- អនុម័តគម្រោងថវិកាសម្រាប់ដំណើរការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- ទទួលនិងដោះស្រាយបណ្ដឹងតវ៉ារបស់គណៈមេប្រយោគឬបេក្ខជន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា ៦.-**

សមាជិក **ក.ត.ស.ក.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៧.-**

**ក.ត.ស.ក.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១(មួយ)ឆ្នាំ។

ការប្រព្រឹត្តទៅនៃអង្គប្រជុំនិងរបៀបរបបការងាររបស់ **ក.ត.ស.ក.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ក.ត.ស.ក.**។

**មាត្រា ៨.-**

**គ.ត.ស.គ.** មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ទីប្រឹក្សា ឬព្រឹទ្ធាចារ្យដែលមានបទពិសោធក្នុងការបណ្តុះបណ្តាលវិស័យកសិកម្ម ដើម្បីចូលរួមប្រជុំតាមការចាំបាច់។

**គ.ត.ស.គ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ អន្តរជាតិមួយចំនួនតាមការចាំបាច់។

**មាត្រា ៩.-**

**គ.ត.ស.គ.** មាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋាន **គ.ត.ស.គ.** មានមន្ត្រីបម្រើការងារមកពីក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមកពីក្របខ័ណ្ឌមុខងារសាធារណៈផ្សេងទៀត។

**មាត្រា ១០.-**

**គ.ត.ស.គ.** មានប្រភពធនធានមកពី៖

- ថវិកាជាតិដែលជាកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ថវិកាដែលបានមកពីការដាក់ពាក្យប្រឡងរបស់បេក្ខជន និង
- ប្រភពផ្សេងៗទៀត។

**មាត្រា ១១.-**

**គ.ត.ស.គ.** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៣
## ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម និងគុណវុឌ្ឍិសម្រាប់ការប្រឡងជ្រើសរើស

**មាត្រា ១២.-**

ឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

- សាស្ត្រាចារ្យជំនួយ
- សាស្ត្រាចារ្យរង និង
- សាស្ត្រាចារ្យ។

**មាត្រា ១៣.-**

បេក្ខជនដែលអាចប្រឡងជ្រើសរើសជាសាស្ត្រាចារ្យទៅតាមកម្រិតនីមួយៗ ដូចមានចែងក្នុងមាត្រា១២ខាងលើនេះបានត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

ក) សាស្ត្រាចារ្យជំនួយ

- មានសញ្ញាបត្របរិញ្ញាបត្រក្រោយបរិញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬក្រសួងអប់រំ យុវជន និងកីឡា ឬសញ្ញាបត្រសមមូល ហើយដែលត្រូវបានទទួលស្គាល់ដោយគណៈកម្មាធិការពិនិត្យវាយតម្លៃកម្រិតសញ្ញាបត្រនិងលិខិតបញ្ជាក់ការសិក្សា
- មាននិក្ខេបបទវិជ្ជាជីវៈឬនិក្ខេបបទស្រាវជ្រាវ
- បានបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ(ឈ្មោះទី១) យ៉ាងតិច៣(បី)នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬ១(មួយ)នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានដឹកនាំធ្វើនិក្ខេបបទយ៉ាងតិចចំនួន៥(ប្រាំ) ឬបានធ្វើជាអ្នកជំនួយការនិក្ខេបបទយ៉ាងតិចចំនួន១០(ដប់)
- បាននិងកំពុងធ្វើការយ៉ាងតិច៦(ប្រាំមួយ)ឆ្នាំ នៅគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្ម នៅស្ថានីយកសិកម្ម នៅអង្គភាពស្រាវជ្រាវកសិកម្ម ឬនៅអង្គភាពនានាក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ជាគ្រូបង្រៀនទ្រឹស្តីយ៉ាងតិច៥(ប្រាំ)ឆ្នាំឬជាគ្រូណែនាំអនុវត្តយ៉ាងតិច៦(ប្រាំមួយ)ឆ្នាំ
- បានបង្រៀនយ៉ាងតិច១(មួយ)មុខវិជ្ជា ដោយឯកភាពផ្សលើមុខជំនាញឯកទេសជាក់លាក់
- បានចងក្រងសៀវភៅសម្រាប់បង្រៀន
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈនិងមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

ខ) សាស្ត្រាចារ្យរង

- បានបម្រើការងារជាសាស្ត្រាចារ្យជំនួយយ៉ាងតិច៤(បួន)ឆ្នាំ ចំពោះសាស្ត្រាចារ្យពេញម៉ោងឬ៥(ប្រាំ)ឆ្នាំចំពោះសាស្ត្រាចារ្យមិនពេញម៉ោង
- បានបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ(ឈ្មោះទី១)យ៉ាងតិច៣(បី)នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬ២(ពីរ)នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសីទអន្តរជាតិដោយធ្វើបទឧទ្ទេសចំនួន២(ពីរ)ដងឬបទបង្ហាញជាផ្ទាំងរូបភាពយ៉ាងតិច៤(បួន)លើក
- បានចងក្រងសៀវភៅដែលពាក់ព័ន្ធនឹងឯកទេស
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈនិងមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

គ) សាស្ត្រាចារ្យ

- បានបម្រើការងារជាសាស្ត្រាចារ្យរងយ៉ាងតិច៥(ប្រាំ)ឆ្នាំ ចំពោះសាស្ត្រាចារ្យពេញម៉ោងឬ៦(ប្រាំមួយ)ឆ្នាំចំពោះសាស្ត្រាចារ្យមិនពេញម៉ោង
- បានបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ(ឈ្មោះទី១)យ៉ាងតិច៤(បួន) នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រក្នុងស្រុក ឬ៣(បី)នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រអន្តរជាតិ
- បានចូលរួមសន្និសីទអន្តរជាតិដោយធ្វើបទឧទ្ទេសចំនួន៣(បី)ដងឬបទបង្ហាញជាផ្ទាំងរូបភាពយ៉ាងតិច៦(ប្រាំមួយ)លើក
- មិនធ្លាប់មានកំហុសវិជ្ជាជីវៈនិងមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ។

# ជំពូកទី៤
# នីតិវិធីនៃការជ្រើសរើស
## ផ្នែកទី១
## នីតិវិធីនៃការជ្រើសរើសគណៈមេប្រយោគ

**មាត្រា ១៤._**

សាកលវិទ្យាធិការឬនាយកនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្ម ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគមួយដែលរៀបចំឡើងដោយគណៈកម្មាធិការបច្ចេកទេសនៃគ្រឹះស្ថានរបស់ខ្លួន យោងតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ ទៅ **ក.ត.ស.ក.** ដើម្បីសុំការអនុម័តយល់ព្រម។ **ក.ត.ស.ក.** ត្រូវផ្តល់ការយល់ព្រមឬបដិសេធលើសមាសភាពគណៈមេប្រយោគក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីបដិសេធ **ក.ត.ស.ក.** ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធទៅសាកលវិទ្យាធិការឬនាយកនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្មពាក់ព័ន្ធ ដើម្បីធ្វើការរៀបចំសមាសភាពជាថ្មីឡើងវិញ។ បន្ទាប់ពីទទួលបានការយល់ព្រមលើសមាសភាពគណៈមេប្រយោគ សាកលវិទ្យាធិការឬនាយកនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្មពាក់ព័ន្ធ ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគនេះទៅរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការតែងតាំង។

**មាត្រា ១៥._**

គណៈមេប្រយោគដែលទទួលបានការតែងតាំង មានឆន្ទានុសិទ្ធិក្នុងការវាយតម្លៃលើបេក្ខជន ដើម្បីទទួលបានឋានៈសាស្ត្រាចារ្យណាមួយ។

**មាត្រា ១៦._**

សមាសភាពគណៈមេប្រយោគសម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យ ត្រូវមានដូចខាងក្រោម៖

ក) សាស្ត្រាចារ្យជំនួយ

សមាសភាពគណៈមេប្រយោគមានចំនួន៧(ប្រាំពីរ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងនិងមានអតីតភាពយូរជាងគេជាប្រធាន
- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យជំនួយជាសមាជិក ដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យក្នុងឋានៈណាមួយមកពីដេប៉ាតឺម៉ង់នៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

ខ) សាស្ត្រាចារ្យរង

សមាសភាពគណៈមេប្រយោគមានចំនួន៧(ប្រាំពីរ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានអតីតភាពយូរជាងគេជាប្រធាន
- សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងជាសមាជិក ដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យឬសាស្ត្រាចារ្យរងមកពីដេប៉ាតឺម៉ង់នៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

គ) សាស្ត្រាចារ្យ

សមាសភាពគណៈមេប្រយោគមានចំនួន៥(ប្រាំ)រូប ដូចខាងក្រោម៖

- សាស្ត្រាចារ្យដែលមានអតីតភាពយូរជាងគេជាប្រធាន
- សាស្ត្រាចារ្យចំនួន២(ពីរ)រូបជាសមាជិក
- សាស្ត្រាចារ្យដែលអញ្ជើញមកពីគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្មដទៃទៀតឬសាស្ត្រាចារ្យបរទេស ចំនួន២(ពីរ)រូបជាសមាជិក។

## ផ្នែកទី២
## នីតិវិធីនៃការប្រឡងជ្រើសរើសសាស្ត្រាចារ្យនិងការផ្តល់ឋានៈ

**មាត្រា ១៧.-**

ចំនួនសាស្ត្រាចារ្យគ្រប់កម្រិតរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗក្នុងវិស័យកសិកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ១៨.-**

បេក្ខជនដែលមានបំណងប្រឡងដើម្បីទទួលឋានៈសាស្ត្រាចារ្យក្នុងវិស័យកសិកម្ម ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យស្នើសុំទៅគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្ម ដោយភ្ជាប់មកជាមួយនូវ៖

- ពាក្យស្នើសុំប្រឡងជ្រើសរើស
- ច្បាប់ចម្លងសញ្ញាបត្រវិជ្ជាជីវៈ
- ផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់បេក្ខជន
- លិខិតថ្កោលទោស
- ឯកសារផ្សេងៗទៀតតាមការចាំបាច់។

គំរូពាក្យស្នើសុំសម្រាប់ការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ឧ.ស.ក.**។

**មាត្រា ១៩.-**

បែបបទនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **គ.ឧ.ស.ក.**។

**មាត្រា ២០.-**

សាកលវិទ្យាធិការឬនាយកនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យកសិកម្ម ត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគទៅ **គ.ឧ.ស.ក.** ដើម្បីសុំការយល់ព្រម។ រាល់ការជំទាស់ណាមួយរបស់ **គ.ឧ.ស.ក.** ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់អំពីមូលហេតុនៃការជំទាស់។

ក្នុងករណីមានវិការៈខាងទម្រង់ណាមួយក្នុងនីតិវិធីនៃការប្រឡងជ្រើសរើសដែលអាចធ្វើនិយតកម្មបាន **គ.ឧ.ស.ក.** ត្រូវធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ ដោយតម្រូវឲ្យគណៈមេប្រយោគកែតម្រូវឡើងវិញ។

បេក្ខជនដែលមិនយល់ព្រមនឹងលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ មានសិទ្ធិប្ដឹងតវ៉ាទៅ **គ.គ.ស.ក.** ដើម្បីស្នើសុំពិនិត្យឡើងវិញ។ ក្នុងការពិនិត្យលើបណ្ដឹងតវ៉ានេះ **គ.គ.ស.ក.** ត្រូវផ្ដល់អាទិភាពដល់គោលការណ៍ឆន្ទានុសិទ្ធិរបស់គណៈមេប្រយោគ ដែលមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ។

នីតិវិធីនៃការដោះស្រាយបណ្ដឹងតវ៉ារបស់បេក្ខជន ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ **គ.គ.ស.ក.**។

**មាត្រា ២១.-**

បន្ទាប់ពីទទួលបានការយល់ព្រមពី **គ.គ.ស.ក.** លើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ និងមិនមានការប្ដឹងតវ៉ាណាមួយលើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ សាកលវិទ្យាធិការឬនាយកនៃគ្រឹះស្ថានបណ្ដុះបណ្ដាលវិស័យកសិកម្មពាក់ព័ន្ធ ត្រូវបញ្ជូនលទ្ធផលប្រឡងរបស់បេក្ខជនជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំការតែងតាំង។

ការផ្ដល់ឋានៈជាសាស្ត្រាចារ្យជំនួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការផ្ដល់ឋានៈជាសាស្ត្រាចារ្យរង ត្រូវកំណត់ដោយអនុក្រឹត្យ។

ការផ្ដល់ឋានៈជាសាស្ត្រាចារ្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ជំពូកទី៥
## បន្ទុកការងាររបស់សាស្ត្រាចារ្យ

**មាត្រា ២២.-**

បន្ទុកការងាររបស់សាស្ត្រាចារ្យតាមកម្រិតនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២៣.-**

ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន នៅពេលដែលមិនទាន់មានសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ រាជរដ្ឋាភិបាលត្រូវរៀបចំតែងតាំងផ្ដល់ឋានៈជាសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យមួយចំនួនតាមការចាំបាច់ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលស្នើឡើងដោយយកលក្ខណៈវិនិច្ឆ័យចែងក្នុងមាត្រា១៣ជាមូលដ្ឋាន។

# ជំពូកទី៧
# អវសានប្បញ្ញត្តិ

**មាត្រា ២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៥ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

លេខ ០១៥ ចល.កសក

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនិងបញ្ជូនមក :

-ឯកឧត្តមថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

« ដើម្បីជូនជ្រាប »

-ឯកឧត្តម លោកប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

« ដើម្បីផ្សព្វផ្សាយ »

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០១២

**តប រដ្ឋមន្ត្រី**

**អគ្គលេខាធិការ**